ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រងដីរដ្ឋ

*****

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១/នស/០៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្តក្រុង

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/០៥ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីព្រៃឈើ

- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្ដីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី

- បានឃើញអនុក្រឹត្យ លេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០០២ ស្ដីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី

- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្ដីពីការចុះបញ្ជីដីធ្លីដែលមានលក្ខណៈដាច់ដោយដុំ

- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្ដីពីសម្បទានដីសង្គមកិច្ច

- បានឃើញអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៥ ស្ដីពីនីតិវិធី ការបង្កើត ការចាត់ថ្នាក់ និងការចុះបញ្ជីកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍

- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០០៥

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

មាត្រា ១ :-

អនុក្រឹត្យនេះមានគោលដៅកំណត់គោលការណ៍ នីតិវិធី យន្តការ និងការរៀបចំផ្នែកស្ថាប័នសម្រាប់ការគ្រប់គ្រងដីរដ្ឋ លើ ÷

- ការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ
- ការចុះបញ្ជី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ
- ការបង្កើត និងការថែរក្សាប្រព័ន្ធទិន្នន័យដីរដ្ឋ
- ការបែងចែក និងការគ្រប់គ្រងដីរដ្ឋ និង
- ការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញ ។

## មាត្រា ២ .

ពាក្យបច្ចេកទេសទាំងឡាយខាងក្រោមនេះមានន័យដូចតទៅ ÷

- ដីរដ្ឋ សំដៅដល់ ដីទាំងអស់ដែលជារបស់រដ្ឋ ហើយដែលឋិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង ឬស្ថាប័នថ្នាក់ជាតិ និងដីដែលត្រូវបានប្រគល់ឱ្យនីតិបុគ្គលសាធារណៈ ឬគ្រឹះស្ថានសាធារណៈដែលបានទទួលស្គាល់ដោយច្បាប់ថា ជានីតិបុគ្គលដើម្បីកាន់កាប់ ។
- អាជ្ញាធរដែនដី សំដៅដល់ រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ។
- អាជ្ញាធរកាន់កាប់ដីរដ្ឋ សំដៅដល់ ក្រសួង ឬ ស្ថាប័ន ឬ អាជ្ញាធរដែនដីដែលរដ្ឋបានប្រគល់ដីរដ្ឋណាមួយជាក់លាក់សម្រាប់គ្រប់គ្រង ថែរក្សាការពារ និងប្រើប្រាស់បំរើឱ្យស្ថាប័ន ។
- ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ សំដៅដល់ក្រុមការងារធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីរដ្ឋ តាមស្រុក ខណ្ឌ។

## មាត្រា ៣ ..

គោលការណ៍ទូទៅសម្រាប់អនុវត្តក្នុងការគ្រប់គ្រងដីរដ្ឋមានដូចខាងក្រោម ÷

ក. ជាទូទៅ រដ្ឋគឺជាម្ចាស់នៃដីទាំងអស់ដែលមិនឋិតនៅក្រោមការកាន់កាប់ជាភោគៈស្របច្បាប់ ឬជាកម្មសិទ្ធិដោយបុគ្គលឯកជន ឬដោយសមូហភាព ស្របតាមច្បាប់ភូមិបាលឆ្នាំ ២០០១ ។

ខ. ដីរដ្ឋរួមមាន ដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ ។

គ. ក្បាលដីរដ្ឋនីមួយៗត្រូវចុះបញ្ជី ជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ នៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ។

ឃ. ដីរដ្ឋអាចផ្តល់ឱ្យជាសម្បទានដីសង្គមកិច្ច ជាសម្បទានដីសេដ្ឋកិច្ច ឬជាសម្បទានផ្សេងៗទៀតបានលុះត្រាតែដីនោះត្រូវបានចុះបញ្ជីថា ជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ និងត្រូវអនុវត្តតាមនីតិវិធីច្បាប់ ។

## មាត្រា ៤ ..

ដីសាធារណៈរបស់រដ្ឋជាដីដែលមានជាប់ផលប្រយោជន៍សាធារណៈ និងឋិតនៅក្នុងប្រភេទជាក់លាក់នៃទ្រព្យដែលមានផលប្រយោជន៍សាធារណៈដូចខាងក្រោម ÷

ក. ទ្រព្យទាំងឡាយដែលបង្ហាញការកើតឡើងពីធម្មជាតិ ដូចជា ÷

១. ព្រៃឈើ ។

២. ផ្លូវទឹកដែលនាវា ឬក្បូនអាចចេញចូលបាន បណ្តែតបាន ។

៣. បឹងធម្មជាតិ ។

៤. ច្រាំងទន្លេដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបាន ។

៥. ត្រើយសមុទ្រ ។

ខ. ទ្រព្យទាំងឡាយដែលជាកម្មវត្ថុនៃការរៀបចំពិសេសសម្រាប់ប្រយោជន៍សាធារណៈទូទៅ ដូចជា ÷

១. កំពង់ផែ ។

២. កំពង់ផែ ។

៣. ផ្លូវដែក ។

៤. ស្ថានីយរថភ្លើង ។

៥. ព្រលានយន្តហោះ ។

គ. ទ្រព្យទាំងឡាយដែលត្រូវបានដាក់ឱ្យប្រើប្រាស់ជាសាធារណៈ តាមស្ថានភាពពីកំណើត ឬក្រោយពីបានរៀបចំ ដូចជា ÷

១. ផ្លូវថ្នល់ ។

២. ផ្លូវលំ ។

៣. ផ្លូវរទេះ ។

៤. ផ្លូវដើរ ។

៥. សួនច្បារ ឧទ្យានសាធារណៈ ។

៦. ដីចំណី ។

ឃ. ទ្រព្យទាំងឡាយដែលត្រូវបានដាក់ឱ្យដំណើរការសម្រាប់សេវាសាធារណៈ ដូចជា ÷

១. សាលារៀន ឬ អគារសិក្សាសាធារណៈ ។

២. អគាររដ្ឋបាល ។

៣. មន្ទីរពេទ្យសាធារណៈ ។

ង. ដែនបម្រុងធម្មជាតិការពារដោយច្បាប់ ។

ច. បេតិកភណ្ឌបុរាណវិទ្យា វប្បធម៌ និងប្រវត្តិសាស្ត្រ ។

ឆ. អចលនវត្ថុជាព្រះរាជទ្រព្យ ដែលមិនមែនជាទ្រព្យសម្បត្តិឯកជនរបស់ព្រះរាជវង្សានុវង្ស ។

ជ. ដីផ្សេងៗទៀតដែលមានចរិតបំរើផលប្រយោជន៍សាធារណៈ និងដីដែលមានមូលដ្ឋានគតិយុត្តកំណត់រួចហើយ ។

មាត្រា ៥ ..

ដីឯកជនរបស់រដ្ឋ រួមមាន ដីទាំងអស់ដែលមិនមែនជាដីសាធារណៈរបស់រដ្ឋ និងមិនមែនជាដីដែលកាន់កាប់ជាកោតៈស្របច្បាប់ ឬជាកម្មសិទ្ធិដោយបុគ្គលឯកជន ឬដោយសមូហភាព ស្របតាមច្បាប់ភូមិបាលឆ្នាំ ២០០១ ។ ដីឯកជនរបស់រដ្ឋ មានរួមបញ្ចូលដូចជា ទ្រព្យនិទាយាទភាពទាំងអស់ ឬទ្រព្យដែលម្ចាស់ប្រគល់ឱ្យរដ្ឋដោយស្ម័គ្រចិត្ត ឬទ្រព្យដែលមិនអាចកំណត់បាននូវអត្តសញ្ញាណកោតិ ឬកម្មសិទ្ធិករស្របច្បាប់ ។

## ជំពូកទី ២

## ការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ

មាត្រា ៦ .-

ក. ការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ ជាដំណើរការមួយដែលមានលក្ខណៈសម្របសម្រួល និងមានតម្លាភាព ធ្វើឡើងដោយក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ក្រោមការដឹកនាំរបស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង ដើម្បីប្រមូល និងចងក្រងឯកសារដូចខាងក្រោម ៖

១. ទីតាំង និងព្រំប្រទល់ប្រហាក់ប្រហែលនៃដីរដ្ឋ ។

២. ព័ត៌មាននានាដែលមានប្រយោជន៍សម្រាប់ការចុះបញ្ជីដីរដ្ឋថា ជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ។

៣. ព័ត៌មានអំពីប្រភេទដី និងការប្រើប្រាស់បច្ចុប្បន្ន ប្រសិនបើមាន។

ខ. ការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ ត្រូវធ្វើឡើងដោយកិច្ចសហការរួមគ្នាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ហើយត្រូវបង្ហាញរាល់ការអះអាងទាំងអស់របស់ក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីនោះទាក់ទងនឹងឋានៈនៃដី និងអាណត្តិកាន់កាប់ ។

គ. តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ មានភារកិច្ចផ្តល់ព័ត៌មាន និងឯកសារទាក់ទងនឹងដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋទាំងអស់ដែលឋិតនៅក្រោមអាណត្តិកាន់កាប់របស់ក្រសួងស្ថាប័ននោះ។ អាជ្ញាធរដែនដីមានភារកិច្ចផ្តល់ព័ត៌មានទាក់ទងនឹងដីសាធារណៈរបស់រដ្ឋ ឬដីឯកជនរបស់រដ្ឋទាំងអស់ដែលឋិតនៅក្នុងដែនដីរបស់ខ្លួន ទោះបីដីនោះឋិត ឬមិនឋិតនៅក្រោមអាណត្តិកាន់កាប់របស់ខ្លួនក៏ដោយ ។

ឃ. តំណាងរបស់ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីណាមួយដែលអះអាង អំពីអាណត្តិកាន់កាប់លើក្បាលដីណាមួយជាកម្មសិទ្ធរបស់រដ្ឋ ឬអះអាងថា ជាដីសាធារណៈរបស់រដ្ឋ ត្រូវផ្តល់ព័ត៌មាន និងឯកសារគាំទ្រ ។

ង. រាល់ព័ត៌មានដែលប្រមូលបានពីការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ ត្រូវចាត់ទុកជាព័ត៌មានបឋម និងមិនទាន់មានការបញ្ជាក់ច្បាស់លាស់ជាផ្លូវការ រហូតដល់ដីនោះត្រូវបានចុះបញ្ជីនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ។

មាត្រា ៧ .-

ក. ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌត្រូវបំពេញកិច្ចការនៃការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋដោយមានជំនួយបច្ចេកទេសពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ខ. ក្រុមការងារដីរដ្ឋថ្នាក់ស្រុកខណ្ឌត្រូវប្រមូលព័ត៌មានទាក់ទងនឹងដីរដ្ឋនៅក្នុងឃុំ សង្កាត់ ពីសមាជិកក្រុមការងាររបស់ខ្លួន និងពីតំណាងរបស់រាល់ស្ថាប័នរដ្ឋ និងអាជ្ញាធរដែនដីនៃឃុំ សង្កាត់នីមួយៗក្នុងស្រុក ខណ្ឌ ។

គ. ក្រុមការងារដីរដ្ឋថ្នាក់ស្រុកខណ្ឌត្រូវរៀបចំរបាយការណ៍ការងារ ដែលមានបញ្ចូលព័ត៌មានដូចបានរៀបរាប់ក្នុងមាត្រា ៦ ក ផែនទីបង្ហាញពីការអះអាងរបស់តំណាងក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីទាំងអស់ ព្រមទាំងសេចក្តីសង្ខេបអំពីមតិសាធារណៈ។

ឃ. ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌត្រូវរកការឯកភាពគ្នាក្នុងចំណោមក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីទាំងអស់ដែលមានការពាក់ព័ន្ធ។ ប៉ុន្តែ ប្រសិនបើមិនអាចសម្រេចបាននូវការឯកភាពមតិគ្នាទេ នោះក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌត្រូវបញ្ជាក់អំពីការអះអាងដែលមិនស្របគ្នាទាំងឡាយនៅក្នុងរបាយការណ៍ ដែលត្រូវដាក់ជូនទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង។

ង. មុននឹងដាក់របាយការណ៍ការងារជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ត្រូវធ្វើការបិទផ្សាយជាសាធារណៈរយៈពេល ៣០ (សាមសិប) ថ្ងៃ នូវសេចក្តីសង្ខេបពីការអះអាងអំពីផែនទីបង្ហាញពីការអះអាង និងសេចក្តីពន្យល់ច្បាស់លាស់អំពីគោលបំណងនៃការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ សម្រាប់ឱ្យសាធារណជនចូលរួមផ្តល់មតិយោបល់ និងត្រូវផ្តល់ជូនតាមការស្នើសុំ នូវសំណៅចំតចម្លងនៃឯកសារដែលបានបិទផ្សាយ ដោយតម្រូវឱ្យបង់ថ្លៃសមស្រប។

ច. ក្រុមការងារដីរដ្ឋថ្នាក់ស្រុកខណ្ឌ ត្រូវធ្វើការសង្ខេបមតិយោបល់សាធារណៈដែលទទួលបាន ហើយបញ្ចូលសេចក្តីសង្ខេបនោះ ទៅក្នុងរបាយការណ៍ការងាររបស់ខ្លួន ដើម្បីដាក់ជូនទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង។

ឆ. ប្រសិនបើមានការអះអាងមិនស្របគ្នា គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង ត្រូវធ្វើការស៊ើបអង្កេតការអះអាងរបស់ស្ថាប័ន ឬអាជ្ញាធរដែនដី តាមការបង្ហាញនៅក្នុងរបាយការណ៍របស់ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ និងត្រូវពិចារណារាល់មតិយោបល់សាធារណៈដែលបានសង្ខេបបញ្ចូលនៅក្នុងរបាយការណ៍នោះ។

ជ. ប្រសិនបើគ្មានការអះអាងដែលមិនស្របគ្នា ឬប្រសិនបើគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង អាចសម្រេចបានការឯកភាពមតិគ្នាលើការអះអាងដែលមិនស្របគ្នានោះ លទ្ធផលនៃការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ ត្រូវបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋដែលត្រូវបង្កើតឡើងស្របតាមអនុក្រឹត្យនេះ។

ឈ. ប្រសិនបើគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុងមិនអាចសម្រេចបានការឯកភាពមតិគ្នាលើការអះអាងដែលមិនស្របគ្នា លទ្ធផលនៃការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ រួមទាំងព័ត៌មានអំពីការអះអាងដែលមិនស្របគ្នានោះ ត្រូវបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋ។

ញ. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវចេញប្រកាសណែនាំលំអិត ស្តីពីការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ និងអំពីក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ។ ប្រកាសណែនាំនេះត្រូវមានបញ្ចូលលក្ខខណ្ឌលំអិតសម្រាប់ឱ្យសាធារណជនទូទៅ និងអាជ្ញាធរប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិចបានដឹងឮ អំពីការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួន និងផ្តល់ឱកាសគ្រប់គ្រាន់ដល់សាធារណជន និងសហគមន៍ជនជាតិដើមភាគតិចបានចូលរួមផ្តល់មតិយោបល់ លើរបាយការណ៍របស់ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ។

## ជំពូកទី ៣
## ការចុះបញ្ជីដីរដ្ឋ

### មាត្រា ៨ ._

ក. ការចុះបញ្ជីដីរដ្ឋត្រូវធ្វើឡើងផ្អែកលើការចុះបញ្ជីដែលមានលក្ខណៈជាប្រព័ន្ធ អនុលោមតាមអនុក្រឹត្យស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ឬផ្អែកលើការចុះបញ្ជីដែលមានលក្ខណៈដាច់ដោយដុំ អនុលោមតាមអនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លីដាច់ដោយដុំ ។

ខ. ដំណើរការចុះបញ្ជីដីរដ្ឋ រួមមាន ÷

១. ការបញ្ជាក់កម្មសិទ្ធិរបស់រដ្ឋលើដី ។

២. ការកំណត់ព្រំប្រទល់ច្បាស់លាស់លើដី ។

៣. ការដោះស្រាយទំនាស់ដោយអាជ្ញាធរមានសមត្ថកិច្ច ។

៤. ការចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លី ។

គ. ប្រសិនបើមានការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋមុនពេលធ្វើការចុះបញ្ជីដី លទ្ធផលនៃការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋនោះ មិនមែនជាព័ត៌មានសម្រេចឡើយ តែជាព័ត៌មានបឋមសម្រាប់ប្រើប្រាស់ ក្នុងដំណើរការចុះបញ្ជីដីរដ្ឋ ។

ឃ. ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដី ដែលអះអាងថា ក្បាលដីរដ្ឋណាមួយជាដីសាធារណៈរបស់រដ្ឋ ត្រូវផ្តល់ឯកសារ និងភស្តុតាងផ្សេងៗទៀតដែលបង្ហាញថា ដីនោះត្រូវបានរាប់បញ្ចូលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ ដូចមានចែងក្នុងមាត្រា ១៥ នៃច្បាប់ភូមិបាលឆ្នាំ ២០០១ ។

ង. ក្នុងការចុះបញ្ជីដីលើកដំបូង ដីរដ្ឋដែលមិនបានបង្ហាញឱ្យឃើញថា មានចរិតប្រើប្រយោជន៍សាធារណៈ ដូចមានចែងក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ និងមាត្រា ១៥ នៃច្បាប់ភូមិបាល ត្រូវចុះបញ្ជីជាដីឯកជនរបស់រដ្ឋ ។

### មាត្រា ៩ ._

ក. នៅក្នុងការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធលើកដំបូង ដីរដ្ឋនៅក្នុងតំបន់វិនិច្ឆ័យត្រូវបានកំណត់ព្រំប្រទល់ ហើយដីនោះត្រូវបានចុះក្នុងសៀវភៅគោលបញ្ជីដីធ្លីថា ជាដីរដ្ឋ ។

ខ. ឋានៈជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋត្រូវបានចុះបញ្ជី ប្រសិនបើ

- ការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋត្រូវបានធ្វើចប់មុនការចុះបញ្ជី ដោយគ្មានការអះអាងណាមួយរបស់ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលមិនស្របគ្នា ឬ
- ទោះបីមិនទាន់មានការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋក្តី ប៉ុន្តែមានព័ត៌មានដែលអាចឱ្យធ្វើការសន្និដ្ឋានបាន អំពីឋានៈ និងការប្រើប្រាស់បច្ចុប្បន្ននៃដីនោះ ហើយក្រសួង-ស្ថាប័ន និងអាជ្ញាធរដែនដីទាំងឡាយក៏មានការឯកភាពមតិគ្នាលើឋានៈនៃដីនោះថា ជាដីសាធារណៈរបស់

រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ ។

មាត្រា ១០ ..

ក. ក្នុងការចុះបញ្ជីដីធ្លីដែលមានលក្ខណៈដាច់ដោយដុំលើកដំបូង ដីរដ្ឋដែលមានព្រំប្រទល់ជាក់លាក់ត្រូវបានចុះបញ្ជីដោយមានឋានៈច្បាស់លាស់ ជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ ។

ខ. ត្រូវអនុវត្តនីតិវិធីនៃការធ្វើចំណាត់ថ្នាក់ដីរដ្ឋដែលមានចែងក្នុងជំពូកទី ៤ នៃអនុក្រឹត្យនេះ មុននឹងធ្វើការចុះបញ្ជីដីបាន ចំពោះស្ថានភាពដូចខាងក្រោម ÷

- ការធ្វើអត្តសញ្ញាណកម្ម និងផែនទីដីរដ្ឋត្រូវបានធ្វើរួច ហើយមានការអះអាងមិនស្របគ្នាពីក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដី ឬ
- ដីដែលគ្មានព័ត៌មានច្បាស់លាស់អំពីឋានៈ និង អំពីការប្រើប្រាស់បច្ចុប្បន្ននៃដីនោះ ។

## ជំពូកទី ៤

## ការធ្វើចំណាត់ថ្នាក់ដីរដ្ឋ ជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ

មាត្រា ១១ ..

នីតិវិធីនៃការធ្វើចំណាត់ថ្នាក់ដីរដ្ឋដែលចែងក្នុងជំពូកនេះ ត្រូវយកមកអនុវត្តលើករណី ដូចខាងក្រោម ÷

១. ដីនោះត្រូវបានចុះបញ្ជីថា ជាដីរដ្ឋនៅក្នុងការអនុវត្តការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ប៉ុន្តែដីនោះមិនទាន់ត្រូវបានធ្វើចំណាត់ថ្នាក់ ជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋនៅឡើយ ។

២. ការចុះបញ្ជីដីរដ្ឋមានលក្ខណៈដាច់ដោយដុំលើកដំបូង ចំពោះដីដែលមិនទាន់អាចចុះបញ្ជីបាន ដោយសារហេតុផលដែលរៀបរាប់ក្នុងមាត្រា ១០ ខ ខាងលើ ។

មាត្រា ១២ ..

ក. ក្នុងករណីដែលតម្រូវឱ្យអនុវត្តនីតិវិធីនៃការធ្វើចំណាត់ថ្នាក់ដី អនុលោមតាមជំពូកនេះ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង_ មានភារកិច្ចផ្តល់អនុសាសន៍ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អំពីឋានៈនៃដីនោះ ដោយបញ្ជាក់ថា ការធ្វើចំណាត់ថ្នាក់ដីនោះ អនុលោមតាមច្បាប់ភូមិបាល និងច្បាប់ផ្សេងៗទៀត ។

ខ. ប្រសិនបើបានធ្វើអត្តសញ្ញាណកម្ម និងផែនទីដីរដ្ឋរួចហើយ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង ត្រូវពិចារណារបាយការណ៍របស់ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ ដែលមានរួមបញ្ចូលទាំងមតិយោបល់សាធារណៈ មុនពេលធ្វើការផ្តល់អនុសាសន៍ ។

គ. ប្រសិនបើមិនទាន់បានធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីរដ្ឋទេ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង ត្រូវធ្វើការស៊ើបអង្កេតរាល់ការអះអាងដែលមិនស្របគ្នារបស់ស្ថាប័ន ឬអាជ្ញាធរដែនដី និងផ្តល់ឱកាសឱ្យសាធារណជនចូលរួមមតិលើការធ្វើចំណាត់ថ្នាក់នោះ ។

ឃ. ប្រសិនបើគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង អាចសម្រេចបានការឯកភាពមតិគ្នាលើការធ្វើចំណាត់ថ្នាក់ដីនោះ ជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ អនុលោមតាមច្បាប់ភូមិបាល និងច្បាប់ពាក់ព័ន្ធផ្សេងៗទៀត គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង ត្រូវលើកអនុសាសន៍ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អំពីឋានៈនៃដីនោះ។

ង. ប្រសិនបើក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ យល់ព្រមតាមអនុសាសន៍របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង ក្រសួងត្រូវចុះបញ្ជីចំណាត់ថ្នាក់នៃដីនោះនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ស្របតាមអនុសាស៍។ ប៉ុន្តែ ប្រសិនបើក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មិនយល់ព្រមតាមអនុសាសន៍របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋដីថ្នាក់ខេត្ត ក្រុងទេ ក្រសួងត្រូវបញ្ជូនករណីនោះទៅក្រុមប្រឹក្សាគោលនយោបាយដីធ្លី។

ច. ប្រសិនបើគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុងមិនអាចសម្រេចបានការឯកភាពមតិគ្នា អំពីឋានៈនៃដីនោះទេ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង ត្រូវធ្វើរបាយការណ៍ជូនក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដើម្បីពិចារណាបន្តទៀត។

ឆ. ប្រសិនបើក្រុមប្រឹក្សាគោលនយោបាយដីធ្លីអាចសម្រេចបានការឯកភាពមតិគ្នាអំពីឋានៈនៃដីនោះថា ជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ ផ្អែកលើមូលដ្ឋានច្បាប់ភូមិបាល និងច្បាប់ផ្សេងៗទៀតដែលពាក់ព័ន្ធ ក្រុមប្រឹក្សាគោលនយោបាយដីធ្លីត្រូវផ្តល់អនុសាសន៍ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អំពីការចុះបញ្ជីដីនោះ។

ជ. ប្រសិនបើក្រុមប្រឹក្សាគោលនយោបាយដីធ្លី មិនអាចសម្រេចបានការឯកភាពមតិគ្នាអំពីឋានៈនៃដីនោះទេ ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី ត្រូវបញ្ជូនករណីនោះទៅគណៈរដ្ឋមន្ត្រីដើម្បីសម្រេចលើការធ្វើចំណាត់ថ្នាក់ដីនោះ។

ឈ. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវចុះបញ្ជីចំណាត់ថ្នាក់ដីរដ្ឋនោះនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ស្របតាមសេចក្តីសម្រេចរបស់គណៈរដ្ឋមន្ត្រី។

ញ. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវចេញប្រកាសលំអិតនៃនីតិវិធីការធ្វើចំណាត់ថ្នាក់ដីរដ្ឋ។

## ជំពូកទី ៥

## ការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញ

មាត្រា ១៣ ._

ការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញ គឺជាការប្តូរឋានៈដីរដ្ឋដែលត្រូវបានចុះបញ្ជីថា ជាដីសាធារណៈរបស់រដ្ឋ ឬ ជាដីឯកជនរបស់រដ្ឋរួចហើយ ÷

- ពីដីឯកជនរបស់រដ្ឋទៅជាដីសាធារណៈរបស់រដ្ឋ ឬ
- ពីដីសាធារណៈរបស់រដ្ឋទៅជាដីឯកជនរបស់រដ្ឋ ។

មាត្រា ១៤ ..

ក. លើកលែងតែមានច្បាប់ចែងផ្សេងពីនេះ ការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញត្រូវអនុវត្តតាមនីតិវិធីដែលមានចែងក្នុងជំពូកនេះ ។ (០៤

ខ. ការធ្វើចំណាត់ថ្នាក់ឡើងវិញ ពីដីឯកជនរបស់រដ្ឋទៅជាដីសាធារណៈរបស់រដ្ឋ ត្រូវធ្វើឡើងដោយអនុក្រឹត្យ ។

គ. ការធ្វើចំណាត់ថ្នាក់ឡើងវិញពីដីសាធារណៈរបស់រដ្ឋទៅជាដីឯកជនរបស់រដ្ឋ ត្រូវធ្វើឡើងដោយអនុលោមតាមមាត្រា១៦ នៃច្បាប់ភូមិបាលឆ្នាំ២០០១។

---

មាត្រា ១៥ ..

ក. ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីក្នុងមូលដ្ឋានណាមួយអាចផ្តួចផ្តើមការធ្វើចំណាត់ថ្នាក់ដីរដ្ឋមួយឡើងវិញ ដោយដាក់សំណើជាលាយល័ក្ខណ៍អក្សរជូនទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុងដែលពាក់ព័ន្ធ។ សំណើនោះត្រូវពណ៌នាអំពីដីដែលស្នើសុំឱ្យធ្វើចំណាត់ឡើងវិញ ដោយមានបង្ហាញលេខសម្គាល់ក្បាលដីនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី ហើយត្រូវបញ្ជាក់មូលហេតុជាក់លាក់សម្រាប់ការស្នើឱ្យធ្វើចំណាត់ថ្នាក់ឡើងវិញ។

ខ. ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃបន្ទាប់ពីបានទទួលសំណើ ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង ត្រូវចាត់តាំងក្រុមត្រួតពិនិត្យមួយដែលមានតំណាងរបស់មន្ទីរដែលមានជំនាញបច្ចេកទេសពាក់ព័ន្ធ ដើម្បីត្រួតពិនិត្យសំណើ និងលើកអនុសាសន៍អំពីសំណើនោះ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង។

គ. ក្រុមត្រួតពិនិត្យនោះត្រូវបញ្ចប់ការត្រួតពិនិត្យក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ បន្ទាប់ពីត្រូវបានចាត់តាំងឡើង។ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុងអាចអនុញ្ញាតឱ្យពន្យារពេលមួយដង ឬច្រើនដង ប៉ុន្តែទោះក្នុងករណីណាក៏ដោយក្រុមត្រួតពិនិត្យត្រូវតែបញ្ចប់ការត្រួតពិនិត្យ ព្រមទាំងរបាយការណ៍ស្តីពីការត្រួតពិនិត្យនោះ ក្នុងរយៈពេលមិនលើសពី ៩០ (កៅសិប) ថ្ងៃ គិតចាប់ពីថ្ងៃចាត់តាំង។

ឃ. ក្រុមត្រួតពិនិត្យដែលត្រូវបានចាត់តាំង ត្រូវបិទផ្សាយជាសាធារណៈសម្រាប់រយៈពេល ៣០ (សាមសិប) ថ្ងៃ អំពីការស្នើសុំឱ្យមានការធ្វើចំណាត់ថ្នាក់ឡើងវិញ ។ ក្នុងពេលនោះ ក្រសួង ស្ថាប័ននានា អាជ្ញាធរដែនដី និងអ្នកលើកសំណើ ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាលក្នុងមូលដ្ឋាន ឬសង្គមស៊ីវិល និងប្រជាពលរដ្ឋនៃ ឃុំ សង្កាត់ដែលពាក់ព័ន្ធ អាចផ្តល់មតិយោបល់របស់ខ្លួន ចំពោះសំណើនោះដល់ក្រុមត្រួតពិនិត្យ ប្រសិនបើមាន។

ង. ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីក្រុមត្រួតពិនិត្យបានដាក់ជូនរបាយការណ៍ត្រួតពិនិត្យ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង ត្រូវលើកអនុសាសន៍របស់ខ្លួនជាលាយល័ក្ខណ៍អក្សរជូនក្រុមប្រឹក្សាគោលនយោបាយដីធ្លីថា គួរទទួលយក ឬបដិសេធ ឬតម្រូវឱ្យធ្វើការកែសម្រួលលើសំណើនោះ។

ច. ក្រុមប្រឹក្សាគោលនយោបាយដីធ្លីត្រូវពិនិត្យអនុសាសន៍របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង ហើយលើកអនុសាសន៍ជូនគណៈរដ្ឋមន្ត្រី។

ឆ. ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីក្នុងមូលដ្ឋានដែលលើកសំណើនោះត្រូវរៀបចំឯកសារ ដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រីនូវសេចក្តីព្រាងអនុក្រឹត្យ ឬច្បាប់ស្តីពីការធ្វើចំណាត់ថ្នាក់ដីរដ្ឋជាក់លាក់ឡើងវិញ តាមករណីជាក់ស្តែង

ដោយមានភ្ជាប់ជាមួយនូវអនុសាសន៍របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង និងរួមទាំងអនុសាសន៍របស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លីផង ។

ឃ. នៅពេលដែលអនុក្រឹត្យ ស្តីពីការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញត្រូវបានសម្រេច ឬច្បាប់ស្តីពីការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញត្រូវបានប្រកាសឱ្យប្រើ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបញ្ចូលព័ត៌មាននៃការធ្វើចំណាត់ថ្នាក់ឡើងវិញ ទៅក្នុងប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋ និងត្រូវចុះក្នុងសៀវភៅគោលបញ្ជីដីធ្លី ។

## ជំពូកទី ៦
## ប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋ

មាត្រា ១៦ ៈ

ប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋ ជាទិន្នន័យដែលមានផ្ទុកព័ត៌មាន អំពីដីរដ្ឋដូចខាងក្រោម ÷

១-ព័ត៌មានបឋមមិនទាន់បានបញ្ជាក់ច្បាស់លាស់ ដែលបានមកពីការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ ។

២-ព័ត៌មាន ដែលបង្ហាញថា ដីនោះបានចុះបញ្ជីរួចហើយ ឬមិនទាន់បានចុះបញ្ជី ។

៣-អត្តសញ្ញាណនៃក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដី ដែលមានអាណាព្យាបាលកាន់កាប់ដីនោះ ។

៤-ឯកសារផ្តល់ដោយក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលមានអាណាព្យាបាលកាន់កាប់ដីនោះ ដែលបង្ហាញអំពីការអះអាងពីឋានៈនៃដីនោះ ។

៥-ព័ត៌មានអំពីប្រទានកម្ម សម្បទាន ការជួល ឬបន្ទុកផ្សេងៗទៀតលើដីនោះ ។

មាត្រា ១៧ ៈ

ក. គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង មានភារកិច្ចថែរក្សា និងធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋប្រចាំខេត្តក្រុង ។

ខ. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវកំណត់លក្ខណៈបច្ចេកទេសនៃប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋ និងត្រូវផ្តល់ការគាំទ្រផ្នែកបច្ចេកទេសសម្រាប់ការថែរក្សា និងការធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋ ។

គ. ប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋនេះ បំពេញទិន្នន័យឱ្យបញ្ជីទ្រព្យសម្បត្តិរដ្ឋ ដែលគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបំពេញឱ្យសៀវភៅគោលបញ្ជីដីធ្លី ដែលគ្រប់គ្រងដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ឃ. សាធារណជនមានសិទ្ធិមើលប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋក្នុងថ្ងៃធ្វើការ និងទទួលបានឯកសារថតចម្លង ដោយត្រូវបង់ថ្លៃថតចម្លង ។

## ជំពូកទី ៧
## អាណត្តិកាន់កាប់ដីរដ្ឋ

មាត្រា ១៨ .-

ក. រដ្ឋអាចប្រគល់ឱ្យក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីនូវសិទ្ធិប្រើប្រាស់ជាផ្លូវការ និងភារកិច្ចរក្សាការពារ ដីសាធារណៈរបស់រដ្ឋ ឬដីឯកជនរបស់រដ្ឋ ។ ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលទទួលសិទ្ធិនោះ ហៅថា អាជ្ញាធរកាន់កាប់ដីរដ្ឋ ។

ខ. អាណត្តិកាន់កាប់ដីរដ្ឋ ត្រូវប្រគល់ឱ្យតាមរយៈលិខិតគតិយុត្តជាក់លាក់ ។ អាណត្តិកាន់កាប់ដីឯកជនរបស់រដ្ឋត្រូវប្រគល់ឱ្យតាមនីតិវិធីដែលមានចែងក្នុងជំពូកទី ៨ នៃអនុក្រឹត្យនេះ ។ អាណត្តិនេះអាចត្រូវដកហូតវិញនៅពេលណាក៏បាន ។

គ. អាជ្ញាធរកាន់កាប់ដីរដ្ឋមានសិទ្ធិប្រើប្រាស់ដីនោះ ដើម្បីបំរើបេសកកម្មរបស់ស្ថាប័នខ្លួន និងមានភារកិច្ចការពារដីនោះ ពីការបំពាន ឬការចូលទន្ទ្រានកាន់កាប់នានា ។

ឃ. អាជ្ញាធរកាន់កាប់ដីរដ្ឋ អាចធ្វើប្រតិភូកម្ម សិទ្ធិប្រើប្រាស់ជាផ្លូវការ និងភារកិច្ចរក្សាការពារ ឱ្យទៅមន្ទីរ ឬ ការិយាល័យខ្សែបណ្តោយរបស់ខ្លួនបាន តាមរយៈការចេញលិខិតផ្លូវការដែលបញ្ជាក់ច្បាស់ អំពីទីតាំង និងទំហំដីជាក់លាក់ ព្រមទាំងវិសាលភាពនៃការទទួលខុសត្រូវដែលត្រូវបានធ្វើប្រតិភូកម្ម ។

ង. លើកលែងតែមានច្បាប់ចែងផ្ទុយពីនេះ ការប្តូរពីដីសាធារណៈរបស់រដ្ឋដែលបំរើផលប្រយោជន៍សាធារណៈមួយជាក់លាក់ ទៅបំរើផលប្រយោជន៍សាធារណៈមួយផ្សេងទៀត ត្រូវកំណត់ដោយអនុក្រឹត្យ ។

ច. អាជ្ញាធរកាន់កាប់ដីរដ្ឋគ្មានសិទ្ធិជួល លក់ ផ្ទេរ ធ្វើអំណោយ ឬដោះដូរដីនោះបានឡើយ លើកលែងតែមានកំណត់ក្នុងអនុក្រឹត្យដោយឡែក ។

ឆ. អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ត្រូវទទួលខុសត្រូវ ជាមួយអាជ្ញាធរកាន់កាប់ដីរដ្ឋ ក្នុងកិច្ចការពារដីសាធារណៈ និងដីឯកជនរបស់រដ្ឋ និងត្រូវមានវិធានការទប់ស្កាត់ការបំពាន ឬការចូលទន្ទ្រានកាន់កាប់ដីរដ្ឋ ។

## ជំពូកទី ៨
## ការបែងចែក និងការធ្វើផែនការប្រើប្រាស់ដីឯកជនរបស់រដ្ឋ

មាត្រា ១៩ .-

គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង មានភារកិច្ចធ្វើផែនការបែងចែកសម្រាប់ការប្រើប្រាស់ផ្សេងៗ នូវដីឯកជនរបស់រដ្ឋ ដែលបានចុះបញ្ជីរួចនៅក្នុងខេត្ត ក្រុង ហើយដែលរដ្ឋមិនទាន់បានប្រគល់ទៅឱ្យស្ថាប័នសាធារណៈ ឬអាជ្ញាធរណាមួយកាន់កាប់នៅឡើយ ។

មាត្រា ២០ ៈ

ដីឯកជនរបស់រដ្ឋអាចត្រូវបានបែងចែក សម្រាប់ការប្រើប្រាស់នៅថ្នាក់ខេត្ត ក្រុង ថ្នាក់ស្រុក ខណ្ឌ ឬថ្នាក់ឃុំ សង្កាត់ ដែលត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

មាត្រា ២១ ៈ

ដីឯកជនរបស់រដ្ឋអាចត្រូវបានបែងចែកសម្រាប់ការប្រើប្រាស់ដោយបុគ្គល ឬអង្គភាពឯកជន ឬសមូហភាពតាមរយៈ

១. សម្បទានដីសង្គមកិច្ច អនុលោមតាមអនុក្រឹត្យ ស្តីពីសម្បទានដីសង្គមកិច្ច។

២. សម្បទានដីសេដ្ឋកិច្ច អនុលោមតាមអនុក្រឹត្យ ស្តីពីសម្បទានដីសេដ្ឋកិច្ច។

៣. សម្បទានផ្សេងៗទៀត អនុលោមតាមអនុក្រឹត្យដែលពាក់ព័ន្ធ ព្រមទាំងនីតិវិធី និងបទប្បញ្ញត្តិជាធរមាន។

មាត្រា ២២ ៈ

នីតិវិធីសម្រាប់ការធ្វើផែនការប្រើប្រាស់ដីឯកជនរបស់រដ្ឋនៅក្នុងខេត្ត ក្រុងដែលមានលក្ខណៈចូលរួម និង ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងមហាផ្ទៃ។

## ជំពូកទី ៩
## ការរៀបចំរដ្ឋបាល និងការអនុវត្ត

មាត្រា ២៣ ៈ

យន្តការនៃការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ មានដូចខាងក្រោម ៖

១- គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង មានទីតាំងក្នុងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង និងមានសិទ្ធិប្រើប្រាស់ត្រារបស់សាលាខេត្ត ក្រុង។

២- ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ មានទីតាំងក្នុងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ និងមានសិទ្ធិប្រើប្រាស់ត្រារបស់សាលាស្រុក ខណ្ឌ។

មាត្រា ២៤ ៈ

គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង មានសមាសភាពដូចតទៅ ៖

| | |
|---|---|
| - អភិបាលខេត្ត ក្រុង | ជាប្រធាន |
| - ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង | ជាសមាជិកអចិន្ត្រៃយ៍ |
| - មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្ត ក្រុង | ជាសមាជិក |
| - ស្នងការនគរបាលខេត្ត ក្រុង | ជាសមាជិក |
| - ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ក្រុង | ជាសមាជិក |

- ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ក្រុង ជាសមាជិក
- ប្រធានមន្ទីរបរិស្ថានខេត្ត ក្រុង ជាសមាជិក
- ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្ត ក្រុង ជាសមាជិក
- ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត ក្រុង ជាសមាជិក
- ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ក្រុង ជាសមាជិក
- ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត ក្រុង ជាសមាជិក
- ប្រធានមន្ទីរទេសចរណ៍ខេត្ត ក្រុង ជាសមាជិក
- ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ក្រុង ជាសមាជិក
- នាយខណ្ឌរដ្ឋបាលព្រៃឈើ ដែលជាប់ពាក់ព័ន្ធនឹងខេត្ត ក្រុង ជាសមាជិក
- អគ្គលេខាធិការសាលាខេត្ត ក្រុង ជាសមាជិក

សមាសភាពដែលមានចែងខាងលើ ត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង អាចអញ្ជើញតំណាងមន្ទីរពាក់ព័ន្ធផ្សេងទៀត ចូលរួមជាសមាជិក តាមតម្រូវការនៃករណីនីមួយៗ ។

មាត្រា ២៥ .-

គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង មានមុខងារ និងភារកិច្ចដូចតទៅ ÷

- ដឹកនាំក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌក្នុងការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ
- សម្របសម្រួលជាមួយក្រសួង ស្ថាប័ន អាជ្ញាធរដែនដី អំពីអាណត្តិកាន់កាប់ និងឋានៈនៃដីរដ្ឋ
- ប្រមូល និងចងក្រងឯកសារព័ត៌មានអំពីទីតាំង ឋានៈ និងការប្រើប្រាស់បច្ចុប្បន្ននៃដីរដ្ឋ
- ផ្តល់មតិយោបល់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ឬ ក្រុមប្រឹក្សាគោលនយោបាយដីធ្លី អំពីអាណត្តិកាន់កាប់ និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ ព្រមទាំងការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញ
- ថែរក្សា និងធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋប្រចាំខេត្ត ក្រុង
- សម្រេច និងត្រួតពិនិត្យលើការរៀបចំផែនការសកម្មភាពប្រើប្រាស់ដីថ្នាក់ឃុំ សង្កាត់ ដោយមានការចូលរួមផ្តល់មតិយោបល់លើគម្រោងសម្បទានដីធ្លី និង សហការតាមដានការអនុវត្តគម្រោងទាំងនោះ
- សហការក្នុងការរៀបចំពិគ្រោះយោបល់ជាសាធារណៈលើគម្រោងសម្បទានដីធ្លី
- លើកគម្រោងថវិកាប្រចាំឆ្នាំ និង
- បំពេញការកិច្ចផ្សេងៗទៀត ដូចមានចែងក្នុងអនុក្រឹត្យនេះ។

### មាត្រា ២៦ .-

គណៈកម្មាធិការគ្រប់គ្រងដីវដ្តថ្នាក់ខេត្ត ក្រុង មានលេខាធិការដ្ឋានមួយជាសេនាធិការ ដើម្បីជួយក្នុងកិច្ចការរដ្ឋបាល និងកិច្ចការបច្ចេកទេសមានជាអាទិ៍ ការបញ្ចូលទិន្នន័យ និងព័ត៌មានពីក្រុមការងារដីវដ្តថ្នាក់ស្រុក ខណ្ឌ ការថែរក្សា និងការធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យ និងផែនទីដីវដ្ត។

លេខាធិការដ្ឋានគ្រប់គ្រងដីវដ្តនេះ ដឹកនាំដោយប្រធានមួយរូប ដែលជាអនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ទទួលបន្ទុកការងារសុរិយោដី និងសមាជិកមួយចំនួនតាមការចាំបាច់ ដែលត្រូវតែងតាំងដោយអភិបាលខេត្ត ក្រុង។

លេខាធិការដ្ឋាននេះ មានទីតាំងនៅក្នុងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង។

### មាត្រា ២៧ .-

ក្រុមការងារដីវដ្តថ្នាក់ស្រុក ខណ្ឌ មានសមាសភាពដូចខាងក្រោម ÷

- -អភិបាលស្រុក ខណ្ឌ ជាប្រធាន
- -ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ជាសមាជិកអចិន្ត្រៃយ៍
- -ប្រធានការិយាល័យជំនាញថ្នាក់ស្រុក ខណ្ឌពាក់ព័ន្ធ និងនាយផ្នែករដ្ឋបាលព្រៃឈើដែលពាក់ព័ន្ធ ជាសមាជិក
- - មេឃុំ ចៅសង្កាត់ពាក់ព័ន្ធក្នុងស្រុក ខណ្ឌ ជាសមាជិក

ប្រធាន និងសមាជិកនៃក្រុមការងារដីវដ្តថ្នាក់ស្រុក ខណ្ឌ ត្រូវតែងតាំងដោយអភិបាលខេត្ត ក្រុង ។

### មាត្រា ២៨ .-

ក្រុមការងារដីវដ្តថ្នាក់ស្រុក ខណ្ឌ ត្រូវស្ថិតក្រោមការណែនាំផ្នែករដ្ឋបាលពីគណៈកម្មាធិការគ្រប់គ្រងដីវដ្តថ្នាក់ខេត្ត ក្រុង និងក្រោមការណែនាំផ្នែកបច្ចេកទេសពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ចំពោះដីវដ្តនៅតាមបណ្ដោយព្រំដែនជាមួយប្រទេសជិតខាងទាំងបី ក្រុមការងារដីវដ្តថ្នាក់ស្រុក ខណ្ឌ និងគណៈកម្មាធិការគ្រប់គ្រងដីវដ្តថ្នាក់ខេត្ត ក្រុង ត្រូវស្ថិតក្រោមការណែនាំផ្នែកបច្ចេកទេសបន្ថែម ពីគណៈកម្មាធិការបច្ចេកទេសនៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន។

មុខងារ និង ភារកិច្ចរបស់ក្រុមការងារដីវដ្តថ្នាក់ស្រុក ខណ្ឌ មានដូចតទៅ ÷

- -ប្រមូល និងចងក្រងឯកសារ ព័ត៌មានដើម្បីធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីវដ្ត
- -សម្របសម្រួលជាមួយស្ថាប័ន អាជ្ញាធរ ឬអ្នកកាន់កាប់ដីវដ្ត អំពីអាណត្តិកាន់កាប់ដីវដ្ត
- -ស្វែងរកការឯកភាពលើព្រំប្រទល់ប្រហាក់ប្រហែល ទំហំ និងការប្រើប្រាស់បច្ចុប្បន្ននៃដីវដ្ត
- -ធ្វើការបិទផ្សាយជាសាធារណៈ នូវសំណើព័ត៌មាន និងផែនទីដីវដ្តនៅតាមទីប្រជុំជន និងតាមឃុំ សង្កាត់ ពាក់ព័ន្ធ និងទទួលមតិយោបល់ពីសាធារណៈ តាមកាលបរិច្ឆេទ និងទីកន្លែងដែលបានកំណត់

-សង្ខេបមតិយោបល់សាធារណៈដែលបានទទួល និងរៀបចំទិន្នន័យ និងឯកសារចាំបាច់ រួមទាំងផែនទីដីរដ្ឋដែលមានបញ្ជាក់ព័ត៌មានទាំងអស់ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង

-ចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី និងផ្តល់មតិយោបល់ក្នុងការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញ

-រៀបចំការពិគ្រោះយោបល់ និងចូលរួមផ្តល់មតិយោបល់លើគម្រោងសម្បទានដីធ្លី ព្រមទាំងសហការតាមដានការអនុវត្តគម្រោងសម្បទានដីធ្លី និង

-បំពេញភារកិច្ចផ្សេងៗទៀត ដូចមានចែងក្នុងអនុក្រឹត្យនេះ ។

## ជំពូកទី ១០

## ប្រភពធនធាន

**មាត្រា ២៩ ៈ**

ថវិកាសម្រាប់ការគ្រប់គ្រងដីរដ្ឋ ដែលរួមមានការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទីដីរដ្ឋ ការធ្វើចំណាត់ថ្នាក់ ការចុះបញ្ជីដីរដ្ឋ ការថែរក្សា និងការធ្វើចរន្តការប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋ ឋិតនៅក្នុងគញ្ចប់ថវិការបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ស្របតាមប្រព័ន្ធថវិកាឯកភាព ធនធាន និងថវិកាសម្រាប់ការគ្រប់គ្រងដីរដ្ឋ បានមកពី ÷

- ថវិកាជាតិ
- ហិរញ្ញប្បទានបានមកពីក្នុង និងក្រៅប្រទេស ឬអង្គការផ្តល់ជំនួយអន្តរជាតិ ។

## ជំពូកទី ១១

## អវសានប្បញ្ញត្តិ

**មាត្រា ៣០ ៈ**

គោលការណ៍ណែនាំអនុវត្តអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

**មាត្រា ៣១ ៈ**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣២ ៈ**

អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**មាត្រា ៣៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការពាក់ព័ន្ធ អភិបាលគ្រប់ខេត្ត ក្រុង គ្រប់ប្រធានស្ថាប័ន អង្គភាពដែលពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងមាត្រា ២៤ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៥

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានទទួលបន្ទុកក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- គ្រប់សាលាខេត្ត ក្រុង
- ដូចមាត្រា ៣៣
- ឯកសារ -កាលប្បវត្តិ